# ការសំភាសន៍របស់អ៊ុំស្រី មាស សុខុន

កៈ អ្នកដែរសំភាសន៍គេ ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ មាស សុខុន

## <u>ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី មាស សុខុន</u>

អ៊ុំស្រី មាស សុខុន មានអាយុ63ឆ្នាំនៅក្នុងឆ្នាំ2018 អ៊ុំស្រី មាស សុខុន មានភេទស្រី អ៊ុំស្រី មាស សុខុន មានទីលំនៅបច្ចុប្បន្ននឹងភូមិតាងៅ ឃុំតាងៅ សង្កាត់នរោទន៍ ខ័ណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឳពុកម្ដាយ នឹងប្រវត្តិរបស់ដូចតារបស់ពួកគាត់ ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ អើយក្មួយចង់ដាក់អីក៏ដាក់ទៅ

កៈ បាទអ៊ុំបាទ?

ខៈ បើក្មួយមកសំភាសន៍អ៊ុំហើយនឹងអ៊ុំនិយាយទៅនឹង

កៈ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរសំភាសន៍មួយនេះត្រូវបាន គឺធ្វើនៅថ្ងៃទី21 ខែ3 ឆ្នាំ2018 សំភាសន៍នៅភូមិនឹងគេហៅភូមិអីគេដែរអ៊ុំ?

ខៈ គេហៅថាភូមិតាងៅ

កៈ នៅភូមិតាងៅ ចុះឃុំអីគេដែរអ៊ុំ?

ខៈ ឃុំតាងៅនឹងដែរ

កៈ អូ៎!!ចឹងនៅភូមិតាងៅ ឃុំតាងៅ សង្កាត់អីគេដែរអ៊ុំ?

ខៈ នៅសង្កាត់នរោទន៍

កៈ អូ៎!!នៅសង្កាត់នរោទន៍ ខណ្ឌចំការមន នៅរាជធានីភ្នំពេញនឹង

ខៈ មានជ័យទេអី រឺក៏ខ័ណ្ឌច្បារអំពៅទេនឹង

កៈ ខ័ណ្ឌច្បារអំពៅហោសអ៊ុំ?

ខៈ ខ័ណ្ឌចំការមនអីណា

កៈ ខ័ណ្ឌច្បារអំពៅ នឹងនៅរាជធានីភ្នំពេញនឹង

ខៈ នៅរាជធានីភ្នំពេញនឹង

កៈ បាទអ៊ុំសំរាប់អ៊ុំមានឈ្មោះពេញនឹងឈ្មោះអីគេដែរទៅអ៊ុំ?

ខៈ អ៊ុំមានឈ្មោះពុំផល្លី

កៈ ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខៈ ឈ្មោះហៅក្រៅនឹងឈ្មោះមាស សុខុន

កៈ ឈ្មោះមាស សុខុន
ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីផ្សេងពីនឹងទៀតទេអ៊ុំ?

ខៈ ហៅតែឈ្មោះខុននឹងច្រើនជាងគេនឹង

កៈ ចឹងហោសអ៊ុំ?

ខៈ ឈ្មោះកំណើតរបស់អ៊ុំនឹងឈ្មោះមាស ផល្លី

កៈ ចុះអ៊ុំសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរទៅអ៊ុំ?

ខៈ អ៊ុំអាយុ63ឆ្នាំហើយ

កៈ  អ៊ុំអាយុ63ឆ្នាំហោសអ៊ុំ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេអ៊ុំ?

ខៈ  អូយអ៊ុំភ្លេចអស់ហើយនឹងទាល់តែអូនឯងនឹងចេះចែកចេះគូរចេះដកអីនឹងហាស

កៈ  បាទអ៊ុំចុះអ៊ុំគិតថាថ្ងៃខែនឹងអ៊ុំមានចងចាំទេអ៊ុំ?

ខៈ  អ៊ុំកើតខែផល្គុននឹងមិនដឹងថាខែប៉ុន្មានទេចាំតែខែខ្មែរទេនឹង

កៈ  អូ!!ដល់ខែបារាំងយើងអត់ចាំទេណាអ៊ុំ?

ខៈ  អត់ចងចាំទេមើលយើងចែត្រ ផល្គុន មើលចែត្រខែ3
ផល្គុនខែ3នឹងចែត្រខែ4នឹងកើតខែ3នឹងផល្គុន នឹងនៅខែ3នឹង

កៈ  ចឹងមានន័យថាអ៊ុំកើតនៅខែ3 ប៉ុន្តែថ្ងៃទីនឹងអ៊ុំអត់មានចងចាំទេ?

ខៈ  អត់ទេក្មួយអោយភ្លេចអស់ហើយនឹងអាពតនឹងវាយកសៀវភៅទៅដុកអស់ហើយនឹង

កៈ  បាទចឹងអ៊ុំកើតនៅឆ្នាំ1955អ៊ុំ?

ខៈ  ចា៎!!!ចឹង

កៈ  បាទអ៊ុំឆ្នាំខ្មែរអ៊ុំមានឆ្នាំអីគេដែរអ៊ុំលក្ខណះជូត ឆ្លូវ ខាល ថោះហាសអ៊ុំឆ្នាំអីគេដែរទៅអ៊ុំ?

ខៈ  អ៊ុំនឹងហោសឆ្នាំរ៉ៃក

កៈ  ចឹងអ៊ុំឆ្នាំរ៉ៃកណាអ៊ុំ?

ខៈ  ចា៎!!!ឆ្នាំរ៉ៃកនឹងហើយ

កៈ  បាទចឹងអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ  អ៊ុកើតនៅខេត្តសៀមរាប

កៈ  ប៉ុន្តែនៅភូមិឃុំអីគេដែរអ៊ុំ?

ខៈ  ប៉ុន្តែស្រុកកំណើតរបស់អ៊ុំនឹងនៅស្រុកកំពង់ឃ្លាំង

កៈ  អូ!!បាទអ៊ុំចឹងអ៊ុំជាអ្នក?

ខៈ  អ៊ុំអ្នកទន្លេទេនឹងខាងនេសាទ

កៈ ប៉ុន្តែនៅភូមិអី នឹងឃុំអីគេដែរអ៊ុំ?

ខៈ គេហៅឃមកំពង់ឃ្លាំងនឹងឯង

កៈ នៅឃុំកំពង់ឃ្លាំង ភូមិកំពង់ឃ្លាំង?

ខៈ ឃុំសង្កាត់កំពង់ឃ្លាំង ស្រុកជាក្រែង ខេត្តសៀមរាប

កៈ នៅស្រុកជាក្រាំង?

ខៈ នៅស្រុកជាក្រែង

កៈ ជាស្រុកជាក្រែងហោសអ៊ុំ?

ខៈ ចា៎!!នៅខេត្តសៀមរាបនឹងប៉ុន្តែឥឡូវនឹងនេះគេដូរចូលសូនិគមន៍វិញហើយនឹង

កៈ អូ៎!!បាទអ៊ុំឥឡូវនឹងខ្ញុំឃើញគេដាក់ចូលសូនិគមន៍នឹងអ៊ុំ?

ខៈ ចា៎!!ចូលសូនិគមន៍នឹង នៅខេត្តសៀមរាបនឹង

កៈ បាទអ៊ុំបាទ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ
អ៊ុំមានបងប្អូនចំនួន5នាក់នឹងប៉ុន្តែអាពតសំលាប់អស់មួយចឹងនៅសល់តែ4នាក់ទេនឹងស្រីៗ
ៗនឹង

កៈ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនបើបងរបស់ខ្ញុំនៅនឹងបងគេ
ដល់ពេលដែរអ៊ុំពីបងរបស់ខ្ញុំនឹងខ្ញុំបងគេបង្អស់នឹង

កៈ អូ៎!!ចឹងបងរបស់អ៊ុំនឹងបានស្លាប់បាត់ហើយណាអ៊ុំ?

ខៈ ស្លាប់នៅជំនាន់អាពតគេសំលាប់ចោលនឹងចា៎!!!

កៈ អូ៎!!ចឹងអ៊ុំនៅបងប្អូនតែ4នាក់ទេណាអ៊ុំ?

ខៈ ចា៎!!នៅបងប្អូន4នាក់នឹង

កៈ ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖  មានស្រីទាំងអស់នឹង4នាក់នឹង

ក៖  ប៉ុន្តែបងធំនឹង?

ខ៖  ប្រុសមួយនឹងស្លាប់ហើយនឹងគេសំលាប់ណុង

ក៖  ប៉ុន្តែអ៊ុំអាចប្រាប់ឈ្មោះបងប្អូនរបស់អ៊ុំបានដែរទេ?

ខ៖  បងប្អូនរបស់ខ្ញុំហោសបងរបស់ខ្ញុំអាស្លាប់នឹងមិនបាច់និយាយទេមែន?

ក៖  អាចប្រាប់ឈ្មោះមកគាត់ឈ្មោះអីគេដែរអ៊ុំ?

ខ៖  បងរបស់ខ្ញុំនឹងឈ្មោះពុំ សុផុន

ក៖  ប៉ុន្តែបន្ទាប់មកអ៊ុំ?

ខ៖  ចាំ!!!អ៊ុំនឹងហើយ

ក៖  បន្ទាប់កូនទី3?

ខ៖  កូនទៅ3នឹងឈ្មោះមាស ផល្លា

ក៖  ចុះកូនទី4វិញអ៊ុំ?

ខ៖  កូនទី4នឹងឈ្មោះមាស សុខខេង

ក៖  ចុះពៅគេវិញអ៊ុំ?

ខ៖  ពៅគេនឹងឈ្មោះមាស ទូច

ក៖  អូ៎!!បាទចុះអ៊ុំមានចងចាំសាច់រឿងអីកាលពីអ៊ុំនៅក្មេងៗៗនឹងជាមួយពួកដែរទេអ៊ុំធ្លាប់លេងអីជាមួយ គ្នាដែរទេអ៊ុំ?

ខ៖  កាលណុងខ្ញុំនៅរៀននឹង

ក៖  នៅរៀនប៉ុន្តែអ៊ុំធ្លាប់បានលេងឡឹកបាយឡអី លេងបាយខំអីចឹងទេអ៊ុំ?

ខ៖  ទេមិនដែរបានលេងអីទេក្មួយអើយមានតែទៅដកស្មៅទៅធ្វើជាជ្រក់ស្ពៃប៉ុណ្ណឹងឯងកាលពីជំនាន់អ៊ុំ នឹងគ្មានបានលេងអីនឹងគេទេ

កៈ អូ៎!!ចឹងទេហោសអ៊ំ?

ខៈ

មានតែប៉ុណ្ណឹងឯងហើយនឹងលេងតែជាមួយប្អូនស្រីៗៗនឹងទេនាំគ្នាដកនៅស្រុកអ៊ុំសំបូរអាស្មៅវែងៗ

ណាស់អ៊ុំក៏ដកបានក៏យកទៅធ្វើជាជ្រក់ស្ពៃនឹងធ្វើប្រពៃណីលក់ចឹងទៅមានតែប៉ុណ្ណឹងឯងនឹងគ្មានធ្វើអីគេ ទេនឹងហាស

កៈ អូ៎!!!បាទអ៊ំ?

ខៈ សំរាប់អ៊ុំនឹងមិនសូវជាអ្នកអីប៉ុន្មានដែរទេនឹង

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាអ៊ុំធ្លាប់មានទៅស្រែជាមួយពួកគាត់ដែរទេអ៊ុំ?

ខៈ អត់ទេខ្ញុំធ្លាប់តែធ្វើដាំឪឡឹក ដាំសណ្តែក

កៈ ប៉ុន្តែថ្លាប់ទៅចំការដាំបន្លែអីចឹងហាសអ៊ុំ?

ខៈ អត់ដែរបានជួយផងនឹងបើអ៊ុំនៅរៀននឹង

កៈ អូ៎!!បាទអ៊ុំចុះអ៊ុំគិតថាប្អូនរបស់អ៊ុំនឹងសព្វថ្ងៃគាត់រស់នៅណាដែរអ៊ុំ?

ខៈ ប្អូនរបស់ខ្ញុំនឹងមួយនៅសៀមរាប មួយទៀតនឹងនៅអូរស្មាច់

មួយទៀតនឹងគេនៅភ្នំពេញនឹងដែរប៉ុន្តែ គេនៅជិតស្តុបចំការមននឹងនៅណុង

កៈ ចុះអ្នកនៅសៀមរាបនឹងគេធ្វើអីគេដែរអ៊ុំ?

ខៈ ណែអ្នកនៅសៀមរាបនឹងគេអត់ធ្វើអីគេទេ គេសុំសិល្បហើយនឹង

ចាមីងមួយទៀតនោះ

កៈ នៅអូរស្មាច់នឹងអ៊ុំ?

ខៈ នៅអូរស្មាច់នឹងមិនទាន់សុំសិល្បទេ

កៈ ប៉ុន្តែគាត់រកស៊ីអីគេដែរអ៊ុំ?

ខៈ គេអត់មានរកស៊ីអីគេទេដើរកោសខ្យល់នឹង

ជូនកាលពេលដែរទំនេរពីមើលចៅអីចឹងទៅ ទៅកោសខ្យល់អោយគេ

កៈ អូ៎!!ចឹងមានន័យថាពួកគាត់សុទ្ធតែមានចៅអស់ហើយណាអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះប្អូនរបស់អ៊ុំនៅចំការមននឹងគេធ្វើអីគេដែរអ៊ុំ?

ខៈ ប្អូននៅចំការមននឹងលក់បាយគ្នាដាក់រទេះលក់ចេះឯងនឹង

កៈ អូ៎!!បាទអ៊ុំ ចុះឪពុករបស់អ៊ុំនឹងគាត់ឈ្មោះអីគេដែរអ៊ុំ?

ខៈ ចា៎!!ឪពុករបស់ខ្ញុំនឹងមានឈ្មោះមាស ត្រា

កៈ ចុះគាត់អាយុប៉ុន្មានដែរអ៊ុំមានដឹងទេអ៊ុំ?

ខៈ ប៉ារបស់ខ្ញុំកាលពីគាត់ស្លាប់នឹងគាត់អាយុ64ឆ្នាំ

កៈ ប៉ុន្តែគាត់ស្លាប់ប៉ុន្មានឆ្នាំដែរហើយអ៊ុំ?

ខៈ យូរហើយនឹងតាំងពីឆ្នាំ1984មកម្ល៉េសនឹង

កៈ អូ៎!!តាំងពីឆ្នាំ1984ហោសអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះគាត់កើតនៅណាដែរអ៊ុំមានដឹងអត់អ៊ុំ?

ខៈ ប៉ារបស់ខ្ញុំនឹងគាត់នៅភ្នំពេញនឹងដែរនឹង

កៈ គាត់កើតនៅភ្នំពេញនឹងតែម្តងនឹងហោសអ៊ុំ?

ខៈ ចា៎!!!នឹងហើយ

កៈ ចុះគាត់កើតនៅណាដែរនៅភ្នំពេញនឹងអ៊ុំ?

ខៈ ស្រុកកំណើតរបស់គាត់នឹងនៅចំការមននឹងហាស

កៈ បាទអ៊ុំចុះម្តាយរបស់អ៊ុំនឹងគាត់ឈ្មោះអីគេដែរអ៊ុំ?

ខៈ ម្តាយរបស់ខ្ញុំនឹងឈ្មោះជា ពេជ្រ

កៈ ចុះកាត់អាយុប៉ុន្មានដែរអ៊ុំមានដឹងទេ?

ខ៖  ម៉ែរបស់ខ្ញុំនឹងអាយុ86ឆ្នាំនឹង

ក៖  ប៉ុន្តែឥឡូវនឹងគាត់?

ខ៖  គាត់បានស្លាប់បាត់ហើយនឹង

ក៖  អូ៎!!បាទចុះគាត់កើតនៅណាដែរអ៊ុំមានដឹងទេអ៊ុំ?

ខ៖  នៅស្រុកកំណើតរបស់គាត់នឹងនៅទន្លេសាបនឹងហើយ

ក៖  អូ៎!!!នៅសៀមរាបនឹងហោសអ៊ុំ?

ខ៖  ចាំ!!នៅកំពង់ឃ្លាំងនឹងហើយ នៅសៀមរាបនឹង

ក៖
បាទអ៊ុំចុះកាលពីឪពុករបស់អ៊ុំនឹងកាលគាត់នៅរស់គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតនឹង ចិញ្ចឹមគ្រួសារដែរអ៊ុំ?

ខ៖  ប៉ារបស់ខ្ញុំនឹងកាលពីគាត់នៅរស់នឹងគាត់ដាំចំការ ដាំសណ្តែកនឹង ឪឡឹកនឹងអ្នកចំការ

ក៖  បាទអ៊ុំចុះគាត់កាច រឺមួយក៏គាត់ស្លូតដែរអ៊ុំ?

ខ៖  ប៉ារបស់ខ្ញុំនឹងស្លូតណាស់មិនដែរចេះវៃកូននឹងជេរកូនអីទេនឹងគាត់ស្លូត ប៉ារបស់ខ្ញុំនឹងកាលពីគាត់នៅ កំលោះហាសគាត់ជាជាងរចនា

ក៖  ធ្វើជាជាងរចនាធ្វើមាស?

ខ៖  ធ្វើព្រះគូររូប គូរអីចឹងទៅយើងសព្វថ្ងៃនឹងគេហៅថាវិស្វករនឹង

ក៖  អូ៎!!វិស្វករណាអ៊ុំណា?

ខ៖  ចាំៗៗ!!នឹង

ក៖  ចុះសំរាប់ម្តាយរបស់អ៊ុំវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖  ម៉ែរបស់ខ្ញុំនឹងអត់មានធ្វើអីគេទេមើលតែកូនទេនឹង

ក៖  ចុះពីមុននឹងគាត់បានប៉ារបស់អ៊ុំនឹងគាត់ធ្វើអីគេដែរអ៊ុំ?

ខ៖  ណែគាត់លើយប្របហុក

កៈ អូ!!លើយប្រហុក?

ខៈ គាត់លើយប្រហុកនឹង ធ្វើប្រហុកធ្វើផ្អកនឹងអ្នកទន្លេនឹងមានតែប៉ុណ្ណឹងឯងនឹង

កៈ បាទអ៊ុំបាទ?

ខៈ កាលពីគាត់នៅក្រមុំហាសណាស់

កៈ បាទអ៊ុំ ចុះកាត់កាចរឺមួយក៏គាត់ស្លូតដែរអ៊ុំ?

ខៈ អូយម៉ែរបស់ខ្ញុំនឹងគាត់កាចណាស់

កៈ គាត់កាចហោសអ៊ុំ?

ខៈ
អត់បានទេគាត់កាចណាស់តិចតិចថាក្រមុំដូចអ៊ុំចេះអីនឹងបើលឺថាមានប្រុសឈ្មោលណាទៅ
និយាយ រកនឹងអត់អោយទៅនិយាយទេនឹង

កៈ អូ!!!ចឹងហោសអ៊ុំ?

ខៈ កាចណាស់ម៉ែរបស់ខ្ញុំនឹង

កៈ បាទចឹងអ៊ុំ?

ខៈ គាត់កាចរហូតទាល់តែគាត់ស្លាប់នឹង

កៈ ចុះកាលអ៊ុំនៅជាមួយពួកគាត់ការពួកគាត់នៅរស់ហាស
អ៊ុំធ្លាប់មានចងចាំរឺក៏ធ្លាប់លេងអីជាមួយ ឪពុកម្តាយរបស់អ៊ុំអត់?

ខៈ អត់ដែរផងនឹង

កៈ លក្ខណះទៅស្រែជាមួយគ្នារឺមួយក៏ទៅចាប់ត្រីអីចឹង?

ខៈ ជួនកាលប៉ាដាក់ទៅជិះទូកទៅចំការចឹងទៅនៅទៅតូចៗនឹងហាសមានទៅធ្វើអីទៅ

កៈ បាទចង់និយាយចឹងហាសអ៊ុំ?

ខ៖
ចាំ!!គាត់ដាក់ខ្ញុំយកទៅៗៗនឹងទៅចំការជាមួយគាត់ដែរចឹងទៅជាមួយកម្មករជាមួយអីចឹងទៅ

ក៖ បាទៗៗអ៊ុំ?

ខ៖ ទៅជាមួយគាត់ឯងទៅមានតែប៉ុណ្ណឹងឯង

ក៖
ចុះអ៊ុំគិតថាឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងនឹងទៅអ៊ុំដែរទេ?

ខ៖ អត់ដែរនិយាយអីផងនឹង

ក៖ ដូចថាកាលពីនៅក្មេងនឹងគាត់ធ្លាប់រកស៊ីអី
កាលណុងគាត់ធ្លាប់មានជួបទុកលំបាកអីចឹង?

ខ៖ កាលណុងគាត់បួសជាសង្ឃ
ដល់គាត់បួសហើយទៅដូចថាគាត់រៀនចេះចប់ចឹងទៅគាត់បួសជាសង្ឃ នឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖
ដល់ពេលដែរបួសជាសង្ឃទៅដល់ពេកដែរគាត់សឹកទៅគាត់តៅស្រុកម៉ែរបស់ខ្ញុំទៅនឹងគាត់ឃើញ ម៉ែរបស់ខ្ញុំនឹងគាត់ក៏ដណ្ដឹងទៅនឹង

ក៖ អូ៎!!បាទអ៊ុំ ចុះម្ដាយរបស់អ៊ុំធ្លាប់ប្រាប់ពីប្រវត្តិអ៊ុំគាត់កាលពីនៅក្មេងទៅអ៊ុំដែរទេ?

ខ៖ ម៉ែនឹងគាត់មិនដែរនិយាយពីប្រវត្តិអីផងនឹង

ក៖ ចឹងអត់ទេណអ៊ុំ ចុះយាយតាខាងម្ដាយនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខ៖ អូយនឹងតារបស់ខ្ញុំនឹងឈ្មោះតានៅ

ក៖ ចុះយាយវិញអ៊ុំ?

ខ៖ យាយឈ្មោះ អូតាឈ្មោះតាជា ហើយជីដូនខ្ញុំនឹងឈ្មោះយាយនៅ

កៈ ប៉ុន្តែខាងនឹងខាងម្តាយ?

ខៈ ខាងម្តាយរបស់ខ្ញុំនឹង

កៈ ចុះខាងឪពុកវិញអ៊ុំ ប៉ុន្តែគាត់មានឈ្មោះអីគេដែរ?

ខៈ ខាងឪពុកនឹងអូយអត់ដឹងទេ

កៈ ប៉ុន្តែខាង?

ខៈ ខាងឪពុកមានណាខាងឪពុកឈ្មោះតាអីទេភ្លេចបាត់ទៅហើយនឹង ឈ្មោះគេហៅអីទេនឹង

កៈ អត់អីទេអ៊ុំបើសិនជាជុំភ្លេចក៏មិនអីដែរអ៊ុំ?

ខៈ ចា៎!!ភ្លេចហើយ

កៈ ចុះយាយតាខាងម្តាយនឹងគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខៈ គាត់កើតនៅស្រុកគាត់នឹងហាស

កៈ ប៉ុន្តែស្រុកគាត់នៅ........?

ខៈ កំពង់ឃ្លាំងនឹងហាស

កៈ អូ៎!នៅកំពង់ឃ្លាំងនឹងហោសអ៊ុំ ចុះអ៊ុំមកនៅទីក្រុងភ្នំពេញនឹងយូរនៅអ៊ុំ?

ខៈ អ៊ុំមកនៅឆ្នាំ1998

កៈ នៅឆ្នាំ1998ចឹងមានន័យថាអ៊ុំនៅអស់20ឆ្នាំហើយណាអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាដែរទៅរស់ក្រៅប្រទេសទេអ៊ុំ?

ខៈ អត់មានទេក្មួយ

កៈ នៅប្រទេសវៀតណាម ប្រទេសថៃអីក៏អត់មានដែរ?

ខៈ អត់មានទេនឹង

ក៖ អូ!!បាទចុះស្វាមីរបស់អ៊ុំនឹងគាត់ឈ្មោះអីគេដែរអ៊ុំ?

ខ៖ ស្វាមីរបស់ខ្ញុំនឹងស្លាប់បាត់ហើយនឹង

ក៖ អូ!!ប៉ុន្តែគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់ឈ្មោះអឹងគឹមលាង ហៅទៅជាកូនទៅវិញហើយនឹងឈ្មោះអឹង គឹមលាង

ក៖ ឈ្មោះអឹង គឹមលាង?

ខ៖ ចាំ!!គាត់ឈ្មោះលាង គឹមលាងនឹងហើយ

ក៖ ចុះអ៊ុំមានចងចាំថាអ៊ុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖ អ៊ុំរៀបការនឹងតាំងពីឆ្នាំ1979នឹង

ក៖ អូ!!នៅឆ្នាំ1979 ចឹងមានន័យថាអស់39ឆ្នាំមែនទេអ៊ុំ?

ខ៖ ចាំ!!នឹងហើយ

ក៖ ចុះនៅពេលដែរប៉ុន្តែថ្ងៃខែអ៊ុំមានចងចាំទេ?

ខ៖ ខែឆ្នាំដែរខ្ញុំការហោស?

ក៖ បាទអ៊ុំបាទ?

ខ៖ ខ្ញុំការខែ11 នៅថ្ងៃ12កើតនឹងខែកក្តិក

ក៖ អូ!!បាទអ៊ុំ ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍នឹងគិតថាអ៊ុំជាអ្នករៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយជាអ្នករៀបចំអោយដែរអ៊ុំ?

ខ៖ ឪពុកម្តាយជាអ្នករៀបចំអោយនឹងក្មួយ

ក៖ ចុះដូចជាតាចូលស្តីដណ្តឹងអ៊ុំនឹងមានជាជំនួនទេអ៊ុំ មានជូនបណ្ណាការអីទៅទេអ៊ុំ?

ខ៖ ជូនដែរតើក្មួយ

ក៖ ជូនអីគេដែរអ៊ុំពេលណុង?

ខ៖ កាលណុងជូនជាមាសនឹងនៅឆ្នាំ1979នឹងគេចាយមាស

កៈ ប៉ុន្តែមាសថោកហាសណាអ៊ុំកាលណុង?

ខៈ បាន7ជីនឹងចាបាន7ជីនឹងជ្រូកមួយ

កៈ អូ៎!!ប៉ុន្តែកាលណុងនឹងលឺថាមាសថោក នឹងលុយថ្លៃហីអ៊ុំ?

ខៈ លុយថ្លៃអត់ទេមាសក៏ថ្លៃដែរនឹងអត់ថោកទេនឹង

កៈ ចឹងហោសអ៊ុំ?

ខៈ ចា៎!!មួយជីនឹងប៉ុន្មានម៉ឺនហោស

កៈ បាទអ៊ុំ ចុះអ៊ុំគិតថាអ៊ុំប្រុសនឹងស្គាល់អ៊ុំតាមរយៈអីគេដែរតៅ?

ខៈ ប្តីរបស់ខ្ញុំហោស?

កៈ បាទអ៊ុំនឹងហើយ?

ខៈ កាលណុងប្តីរបស់ខ្ញុំនឹងគាត់ធ្វើការខាងជល់ផល
គាត់ធ្វើការខាងពីមុនគាត់ចូលធ្វើការនឹង នឹងមច្ចឹមហាស

កៈ បាទអ៊ុំបាទ?

ខៈ
ចា៎!!មច្ចឹមនឹងខាងនេសាទនឹងគាត់មកគាត់មកគាត់ឃើញខ្ញុំចឹងទៅគាត់ដណ្តឹងតែម្តងនឹង
ទៅ គាត់ទៅដណ្តឹងពីម៉ែរបស់ខ្ញុំនឹង

កៈ ប៉ុន្តែគាត់ស្គាល់អ៊ុំយូរនៅពេលណុង?

ខៈ អត់ទេនឹងអ៊ុំអត់ដែរស្គាល់គ្នាទេនឹង ចុះគាត់នៅកំពង់ធំនឹងអ៊ុំនៅសៀមរាបនឹង

កៈ ប៉ុន្តែគាត់ទៅធ្វើការខាងសៀមរាបនឹងហោសអ៊ុំ?

ខៈ
ចា៎!!!គាត់ផ្លាស់ទៅធ្វើការនៅសៀមរាបនឹងទៅត្រូវប៉ារបស់ខ្ញុំនឹងកាលណុងប៉ារបស់ខ្ញុំនឹងគា
ត់ធ្វើ ជាប្រធានភូមិផងនឹងធ្វើសង្កាត់ហាស

កៈ បាទអ៊ុំបាទ?

ខ៖
ដល់ពេលដែរគាត់ឡើងទៅទាក់ទងទៅគាត់ឃើញខ្ញុំនឹងគាត់ក៏ដណ្ដឹងយកទៅនឹងហាស ខ្ញុំគ្មានបានទៅទាក់ទងគ្នាបានដូចខ្ញុំសព្វថ្ងៃណា

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ចុះបើមិនមើលមុខគ្នាចំផងនឹង

ក៖ ចុះអ៊ុំមានចេះភាសាខ្មែរបានកំរិតណាដែរអ៊ុំ?

ខ៖ អ៊ុំរៀនពីសង្គមនឹងបានថ្នាក់ទី10នឹង

ក៖ អូ៎!បានថ្នាក់ទី10 ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខ៖ អត់ទេនឹងចេះតែខ្មែរមួយនឹងបានអ៊ុំ

ក៖ ប៉ុន្តែភាសាថៃ?

ខ៖
ងត់ទេកាលពីអ៊ុំចូលរៀននឹងអ៊ុំរៀនបានថ្នាក់ទី10នឹងរៀនបាន3ខែនឹងក៏រដ្ឋប្រហារនឹងឯងគ្មានបាន រៀនបារាំងនអីណា
ប៉ុន្តែបងប្អូនជីដូនមួយរបស់ខ្ញុំនឹងគាត់ចេះបារាំងរៀនបានថ្នាក់ទី7នឹង

ក៖ ប៉ុន្តែអ៊ុំអត់បានរៀនទេបារាំងនឹង?

ខ៖ គ្មានបានរៀនណាបើទើបតែចូលរៀនបានថ្នាក់ទី10នឹង
ទេគេរៀនចប់ថ្នាក់ទី10នឹងកាលណុង
គេអត់ទាន់ទេទាល់តែថ្នាក់ទី7នឹងបានបង្ហាត់បារាំងនឹង

ក៖ បាទអ៊ុំចុះកាលពីអ៊ុំរៀននឹងអ៊ុំរៀននៅសាលាណាដែរអ៊ុំ?

ខ៖ អ៊ុំរៀននៅស្រុកកំណើតរបស់អ៊ុំដែរនឹង

ក៖ ប៉ុន្តែសាលាឈ្មោះអីគេដែរអ៊ុំមានចងចាំទេ?

ខ៖

សាលាមិនដឹងថាឈ្មោះអីទេក្មួយកាលពីតូចនឹងយូរដែរហើយនឹងចង់100ឆ្នាំដែរហើយនឹង

កៈ  អូ!!បាទអ៊ុំប៉ុន្តែដូចជាអ៊ុំធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខៈ  អត់ដែរមានទេ មានតែបងប្អូនជីដូនមួយឯងនឹង

កៈ  ចុះកាលពីនៅសាលានឹងអ៊ុំមានដែរមានមិត្តភក្តិដែរបានដើរលេងជាមួយគ្នាអីអត់?

ខៈ  អត់ដែរមានទេនឹងកាលពីជំនាន់អ៊ុំនឹងអត់ហ៊ានដើរលេងទេ
ដឹងតែចេញពីសាលាចូលផ្ទះដឹងតែ
ចេញពីផ្ទះនឹងមិនដែរមានពួកម៉ាក់ទេនឹងអ៊ុំមួយជាតិរហូតមកដល់ឥឡូវនឹងមិនដែរមានពួក
ម៉ាក់នឹងគេទេ

កៈ
បាទអ៊ុំបាទចុះអ៊ុំគិតថាធ្លាប់ធ្វើការងារអីគេខ្លះដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស
អ៊ុំ?

ខៈ  ពីក្មេងនឹងហោស?

កៈ  បាទអ៊ុំបាទ?

ខៈ
ពីក្មេងនឹងដល់ពេលដែរអ៊ុំគ្រប់អាយុការនឹងជំនាន់អាពតនឹងឯងគ្មានបានធ្វើការរកស៊ីនៅ
ណា គឺរកស៊ីបំរើអាពតនឹងឯង

កៈ  អូ!!ចុំពីមុនកាលអាពតនឹងអ៊ុំធ្វើអីគេដែរអ៊ុំ?

ខៈ
កាលមុនពីអាពតនឹងមានតែយកប្អូនមើលនឹងមើលការខុសត្រូវនឹងហើយជួយម្តាយនឹង

កៈ  អូ!!បាទអ៊ុំបាទ?

ខៈ  រែកទឹក ដាំបាយមានតែប៉ុណ្ណឹងឯងគ្មានបានធ្វើអីគេទេ

កៈ  ចឹងអ៊ុំអត់បានធ្វើអីទេណាអ៊ុំ?

ខៈ  អត់សោះនឹងហាសចា

កៈ  ប៉ុន្តែអ៊ុំគិតថាអ៊ុំធ្លាប់ទៅធ្វើនៅវាលស្រែទេអ៊ុំលក្ខណះស្រែចំការហោស?

ខ៖ ស្រែចំការនឹងអ៊ុំធ្វើនៅជំនាន់អាពតនឹងគេជំលាសមក

ក៖ ប៉ុន្តែដូចជាអ៊ុំលក្ខណះថាធ្លាប់បើកអាជីវកម្មអីផ្ទាល់ខ្លួនដែរទេអ៊ុំ?

ខ៖
អត់មានទេក្មួយស្រុកអ៊ុំនឹងតែដាំចំការសណ្តែកហើយនឹងគឺហើយៗនឹងគ្មានធ្វើអីគេទេ
នាំគ្នាដេកស៊ីហើយនឹង

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ ដល់ខែរដូវចុះទៅនឹងធ្វូលហើយនឹង

ក៖ បាទចុះទៅប្រមូលផលណាអ៊ុំ?

ខ៖
បានប្រមូលផលនឹងហើយអត់មានថាយើងឡើងមកពីចំការហើយធ្វើអីទៀតនឹងអត់មានទេ
ក្មួយ

ក៖ ចុះអ៊ុំគិតថាអ៊ុំមានធ្លាប់ចិញ្ចឹមសត្វអីទេអ៊ុំដូចជា ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ចិញ្ចឹមទា
ចិញ្ចឹមគោអីចឹង?

ខ៖ អ៊ុំធ្លាប់ដែរកាលនៅពីក្រមុំនឹងអ៊ុំចិញ្ចឹមជ្រូក

ក៖ ចិញ្ចឹមច្រើនអត់អ៊ុំ?

ខ៖ អត់ទេនឹងចិញ្ចឹមជ្រូកតែមួយគូរទេនឹង

ក៖ ចិញ្ចឹមជ្រូកប៉ុន្តែអ៊ុំអត់មានចិញ្ចឹមអីផ្សេងទៀតណាហីអ៊ុំ?

ខ៖
អត់មានទេអត់មានចិញ្ចឹមទេមួយជាតិនេះអត់មានទៅធ្វើបាបជាមួយសត្វណាទេនឹងអត់ទេ

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរទេអ៊ុំ?

ខ៖ ចា៎!!!ដូចជាមិនមានការផ្លាស់ប្តូរអីប៉ុន្មានទេមានតែប៉ុននេះឯងនឹង

ក៖ ចឹងណាអ៊ុំ?

ខ៖ ចាំ!!នឹងហើយ

ក៖ ចុះសុខភាពនឹងយ៉ាងម៉េចដែរអ៊ុំ?

ខ៖ ទេក្មួយសុខភាពនឹងវាមិនអីទេចេះតែទៅហើយពីព្រោះអ៊ុំលក់ដូររាល់តែថ្ងៃនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ ចេះតែទៅហើយនឹង

ក៖ ចុះជីវភាពនឹងយ៉ាងម៉េចដែរអ៊ុំ?

ខ៖ អ៊ុំហោសជីវភាពនឹងអត់ក៏ថាវាមិនអត់នឹងវាកណ្ដាលនឹង

ក៖ ចឹងណោះអ៊ុំ ចុះអ៊ុំគិតថាម្ហូបអីគេដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ?

ខ៖ អ៊ុំហោសក្មួយសព្វថ្ងៃនឹងមិនដឹងថាចូលចិត្តអីផងនឹងមានអីហូបនឹង

ក៖ អូ៎!!!បាទអ៊ុំបាទ?

ខ៖ គ្មានគំរោងការថាចង់ហូបអីនឹងអត់សោះនឹងហាស

ក៖ ប៉ុន្តែស្ងោរ ឆា ចៀនអីដែរអ៊ុំនឹកឃើញថាចង់ហាសដូចខ អីនឹងហាស?

ខ៖ ចាំ!!បើអ៊ុំចង់ខ ក៏ខទៅ បើចង់ឆានឹងក៏ឆាទៅនឹង
បើថាចង់អោយអត់មិនបាននឹងធម្មតាទេ

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ចាំ!!ធម្មតានឹងហាស

ក៖ ចុះអ៊ុំគិតថាកាលពីក្មេងនឹងអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេខ្លះដែរអ៊ុំ?

ខ៖ អ៊ុំនឹងហោសនៅពីក្មេងនឹងចូលចិត្តលេងខ្លាឃ្លោក

ក៖ អូ៎!!លេងខ្លាឃ្លោកហោសអ៊ុំ?

ខ៖ លេងខ្លាឃ្លោកនឹង

ក៖ ចុះលក្ខណះបោះអង្គុញ ចោលឈូង លាក់កន្សែងអីអ៊ុំចូលចិត្តដែរទេ?

ខ៖  ចូលចិត្តលេងឈូង

ក៖  លេងឈូងនឹងហោសអុំ?

ខ៖  កាលពីចូលឆ្នាំនឹងនាំគ្នាលេងហើយកាលនៅក្មេងៗហោស
នាំគ្នាលេងបោះឈូងមុខផ្ទះអីចឹងទៅ

ក៖  អូ៎!ប៉ុន្តែគេអត់លេងនៅវត្តណាហីអុំ?

ខ៖  អត់ទេអុំច្រើនតែទៅលេងនៅផ្ទះមិនដែរទៅលេងនៅវត្ត
ពីព្រោះម៉ែរបស់ខ្ញុំនឹងមិនអោយដើរនោះ

ក៖  ប៉ុន្តែដូចជាដណ្តើមស្លឹកឈើ លេងខ្លែងឆាបកូនមាន់អីនឹងអុំលេងដែរតើហីអុំ?

ខ៖  អត់ទេក្មួយច្រើនតែលេងឈូងនឹងហើយ លេងអង្គុញនឹងហាស

ក៖  អូ៎!!បាទអុំបាទ?

ខ៖  ចា៎!!មានតែប៉ុណ្ណឹងឯងនឹង

ក៖  ចុះជុំចេះច្រៀងដែរទេអុំ?

ខ៖  អុំអត់ចេះទេនឹង

ក៖  ប៉ុន្តែអុំចូលចិត្តស្តាប់បទចំរៀងអត់អុំ?

ខ៖  អុំចូលចិត្តដែរនឹង

ក៖  ប៉ុន្តែលក្ខណៈបទបុរាណ រឺមួយក៏បទសម័យដែរអុំ?

ខ៖  អត់ទេចូលចិត្តបទពីដើមនឹងហាស

ក៖  ប៉ុន្តែអុំចូលចិត្តស្តាប់យីកេអាយៃអីទេអុំ?
ខ៖  ចា៎!!ថាម៉េច?

ក៖  យីកេអាយៃអីនឹងហាសអុំ?

ខ៖  យីកេអាយៃអីនឹងហាសក្មួយកាលពីដើមនឹងចូលចិត្តដែរ

ក៖  ប៉ុន្តែឥឡូវនឹងអុំអត់សូវចូលចិត្តទេមែនអុំ?

ខ៖  ឥឡូវនឹងឯងត់មានឃីកេអីផងនឹង

ក៖  ប៉ុន្តែអ៊ុំចូលចិត្តស្តាប់ធិមដែរណាអ៊ុំ?

ខ៖  ចា៎!!នឹងវិទ្យុអ៊ុំនឹងទើបតែខូចនឹងតើពេលយប់នឹងអ៊ុំបើកស្តាប់ធិមទៅនឹង

ក៖  អូ៎!!បាទអ៊ុំបាទ?

ខ៖  ស្តាប់ចំរៀងចឹងទៅណាស់

ក៖
ចុះអ៊ុំគិតថាមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខ៖  អត់មានទេក្មួយ

ក៖  កូនក្មួយអីនឹងគិតថាពួកគាត់ចេះលេងភ្លេងខ្មែរអីភ្លេងអីទេអ៊ុំ?

ខ៖  អត់សោះតែម្តងនឹង

ក៖  អត់តែម្តងនឹងហោសអ៊ុំ?

ខ៖  អត់មាននរណាគេចេះសោះនឹងហាស

ក៖  អូ៎!!បាទចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរអ៊ុំ?

ខ៖  នឹងគឺផ្ទះជួលនឹងឯង

ក៖  អូ៎!បាទអ៊ុំបាទ?

ខ៖  ជួលគេរហូតនឹងហាសក្មួយ

ក៖  បាទអ៊ុំបាទនឹង?

ខ៖  តាំងពីឆ្នាំ1998នឹងយើងជួលគេរហូតនឹងយើងគ្មានលុយណាទិញទេក្មួយអើយ

ក៖  ប៉ុន្តែកាលពីតូចនឹងផ្ទះយ៉ាងម៉េចដែរអ៊ុំ?

ខ៖  ផ្ទះរបស់ខ្ញុំនឹងហាសកាលពីនៅជុំម៉ែឪខ្ញុំនឹងផ្ទះរបស់ខ្ញុំនឹង ផ្ទះចេះឯងនឹងឈើចេះនឹង ប៉ុន្តែនៅស្រុក ទន្លេនឹងផ្ទះវាខ្ពស់នឹងហោស

កៈ បាទអ៊ុំបាទ?

ខៈ គេធ្វើខ្ពស់នឹងហោស

កៈ ប៉ុន្តែនរណាគេជាង្នកធ្វើផ្ទះមួយនឹងដែរអ៊ុំ?

ខៈ លោកពុករបស់ខ្ញុំនឹងហាស

កៈ ប៉ុន្តែគាត់ចេះធ្វើផ្ទះរឺមួយក៏គាត់ជួលគេធ្វើដែរអ៊ុំ?

ខៈ គាត់ជួលគេធ្វើនឹងហាស

កៈ ប៉ុន្តែនៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងគ្មាននរណាគេចេះធ្វើផ្ទះទេណាអ៊ុំ?

ខៈ អត់មានទេនឹងគ្មាននរណាគេចេះទេនឹង

កៈ អូ៎!!បាទអ៊ុំ ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងគេប្រើឧបករណ៍អីគេដែរសំរាប់សាងសងដែរអ៊ុំ?

ខៈ ណែយើងកាលណុងធ្វើតែឈើនឹងហាស

កៈ ធ្វើពីឈើណាអ៊ុំណា?

ខៈ ចា៎!!ដំបូលស្បូវនឹងហាស

កៈ ចុះអ៊ុំគិតថាមានគ្រឿងប្រើប្រាស់អីមានដូចជាគ្រឿងដែកគោល
មានអីខ្លះដែរទៅចឹងហាស?

ខៈ មានដែកគោលផងទៅមានអីទេច្រើនណាស់ផ្ទះគេធ្វើនឹងហាសមិនសូវដឹងផងនឹង

កៈ អូ៎!!ដូចជាដែកគាស់ ដែកកាប់?

ខៈ ចា៎!!នឹងឯងមានដែកគាស់ ពូថៅរណាអីចឹងទៅនឹង

កៈ បាទអ៊ុំបាទ ចុះអ៊ុំគិតថាជំនាញអីដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខៈ អ៊ុំហោសជំនាញរបស់អ៊ុំនឹងជំនាញធ្វើបង្អែមលក់នឹងហាស

កៈ អូ៎!!អ៊ុំពូកែធ្វើបង្អែមហោសអ៊ុំ?

ខៈ ចា៎!!ធ្វើបង្អែមលក់នឹងក្មួយអស់រយះពេល20ឆ្នាំហើយនឹង

កៈ អូ៎!!ឥឡូវនឹងនៅតែធ្វើចឹងហោសអ៊ំ?
ខៈ ចា៎!!ធ្វើនឹង

កៈ ប៉ុន្តែអ៊ំយកទៅលក់នៅណាវិញទៅអ៊ំ?

ខៈ នេះនៅមុខគណៈបក្សនឹងហាស

កៈ អូ៎!!បាទអ៊ំ
ចុះអ៊ំគិតថាឪពុកម្តាយរបស់អ៊ំនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅអ៊ំដែរទេអ៊ំ?

ខៈ អត់មានទេឪពុកម្តាយរបស់ខ្ញុំនឹងអត់មានបង្ហាត់បង្រៀនជំនាញអីទៅទេនឹង

កៈ ដូចលក្ខណៈថាវេញវល្លិ៍ ក្ងរស្ករត្នោត ធ្វើផ្តៅ ធ្វើកន្ទេលអញ្ចឹតអីចឹងហាស?

ខៈ អត់ទេនឹងអត់សោះនឹងហើយ
កាលពីដើមនឹងកាលណុងអ៊ំនមានប្តីហើយនឹងអ៊ំធ្វើជាអង្រឹងចឹងទៅ

កៈ អូ៎!!អ៊ំចេះធ្វើអង្រឹងហោសអ៊ំ?

ខៈ ចា៎!!អង្រឹងកំប្លោកយើងនឹងហាស

កៈ បាទអ៊ំបាទនឹង?

ខៈ នឹងចេះត្បាញបើថាអោយមានជំនាញអីនឹងគ្មានទេក្មួយ

កៈ ចុះអ៊ំអាចប្រាប់ពីពេលលំបាកកាលពីនៅក្មេងបានទេអ៊ំ
អ៊ំកាលនៅពីក្មេងនឹងអ៊ំមានការលំបាកអីទេអ៊ំ?

ខៈ ទេអ៊ំនៅពីក្មេងនឹងអត់មានការលំបាកអីទេនឹង អ៊ំលំបាកជំនាន់អាពតនឹងឯង

កៈ ចឹងកាលពីជំនាន់ពលពតនឹងអ៊ំមានការលំបាកអីគេខ្លះដែរអ៊ំ?

ខៈ លំបាកណាស់ក្មួយវាអោយយើងរែកដី វាអោយកាប់ភ្លឺស្រែវាអោយស្ទូងស្រូវ
វាអោយច្រូតនឹងបើនិយាយពីជំនាន់ពលពតនឹងវាអោយធករគ្រប់យ៉ាងនឹង

កៈ វាអោយធ្វើច្រើនណាអ៊ំ?

ខៈ វាអោយធ្វើគ្រប់យ៉ាងនឹង

កៈ ប៉ុន្តែពេលណុងគេជំលាសអ៊ុំទៅណាដែរអ៊ុំ?

ខៈ ខ្ញុំគេជំលាសទៅនៅភូមិអូរនឹង ភូមិអូរស្លាកនៅស្រុកលើគេអោយមកនៅស្រុកលើនឹង

កៈ នៅខេត្តណាដែរអ៊ុំ?

ខៈ នៅខេត្តសៀមរាបនឹងដែរ

កៈ នៅខេត្តសៀមរាបនឹងហោសអ៊ុំ
ចុះអ៊ុំនៅណុងរហូត3ឆ្នាំតែម្តងនឹងរឺមួយក៏អ៊ុំមានការផ្លាស់ប្តូរអីផ្សេង ទៀតដែរអ៊ុំ?

ខៈ
ដល់ពេលដែរអ៊ុំជំលាសពីឆ្នាំ1970ដល់ឆ្នាំ1979នឹងបានមកនៅស្រុកវិញដែរយួនចូលមកនឹង

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ចា៎!!នៅបានយូរដែរនឹង

កៈ ប៉ុន្តែពេលណុងអ៊ុំដូចជាអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?
ខៈ
កាលដែរខ្ញុំទៅដំបូងនឹងអាយុ16ឆ្នាំនឹងដល់ពេលដែរខ្ញុំត្រលប់មកវិញនឹងអាយុ23ឆ្នាំនឹង

កៈ ប៉ុន្តែអ៊ុំការនឹងនៅអាយុ23ឆ្នាំនឹង?

ខៈ ចា៎!!ការនៅអាយុ23ឆ្នាំនឹង

កៈ អូ៎!!បាទចុះរបបអាហារយើងនឹងកាលណុងយ៉ាងម៉េចដែរអ៊ុំ?

ខៈ
របបរបស់វានឹងវាអោយយើងឧបម៉ាថាបបរចឹងវាអោយដួសមួយវែកចឹងមកវាកឃ្លោកអោយយើង ហូបចឹងនឹងឯងនឹង

កៈ បាទអ៊ុំ ចុះពេលណុងអ៊ុំអត់នៅជាមួយគ្រួសារទេណាអ៊ុំ?

ខៈ អត់ទេខ្ញុំនៅលីវនឹង

កៈ ចង់និយាយថាអ៊ុំអត់នៅជាមួយឪពុកម្តាយអីទៀតណាហីអ៊ុំ?

ខ៖ អត់ទេគេងោយចល័តនឹងគ្រប់ភូមិ គ្រប់សង្កាត់នឹង

ក៖ ចុះឪពុកម្តាយរបស់អ៊ុំនឹងគេអោយទៅណាដែរពេលណុងអ៊ុំ?

ខ៖ លោកពុកនឹងគេអោយធ្វើណែជាង ហើយម៉ែរបស់ខ្ញុំនឹងគេអោយរែកអាចម៍

ក៖ រែកអាចម៍គោអីនឹងហោសអ៊ុំ?

ខ៖ រែកអាចម៍មនុស្សនឹងណា ធ្វើជាជី

ក៖ អូ៎!!ចឹងហោស?

ខ៖
គេអោយពេលព្រឹកចេះម៉ែរបស់ខ្ញុំនឹងគេអោយបានយកទៅលុបទៅនឹងដួសដាក់បង្គីរែកយក ទៅអោយគេនឹងហាស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ កាលពីជំនាន់អាពតនឹងហាស

ក៖
បាទចុះអ៊ុំដូចជាពេលណុងនៅជំនាន់ពលពតនឹងគេដូចជាមានអោយប្អូនរបស់អ៊ុំទៅណាអីផ្សេងទេ?

ខ៖ ប្អូនរបស់ខ្ញុំនឹងកាលណុងប្អូនរបស់ខ្ញុំនឹងនៅកុមារនឹង
ធំតែប្អូនរបស់ខ្ញុំនឹងទី2ហើយនឹងខ្ញុំមួយទេ

ក៖ ចឹងមានន័យថាប្អូនរបស់អ៊ុំនៅកុមារនឹងគេអោយនៅកងកុមារទេនឹង?

ខ៖ ចាំ!!នឹងហើយខ្ញុំជាកងនារីនឹងគេអោយទៅកងនារីទៅនឹង

ក៖ ប៉ុន្តែគេអោយធ្វើអីធ្ងន់ធ្ងរអត់អ៊ុំ?

ខ៖ អូយរែកដីនឹងរែកតែកន្លះម៉ែត្រនឹងរែកមិនសឹងទាំងចង់រួចទៅហើយនឹង

ក៖ អូ៎!!ប៉ុន្តែគេអោយយើងរែកគ្នាច្រើនមែនទេអ៊ុំ?

ខ៖
មានគ្នាច្រើនហាសណាស់មួយកងៗៗគេនឹងមួយចល័តៗៗនឹងមើលពីរនេះនឹងទៅដល់ច្បារអំពៅ នឹងហាស

ក៖ អូ៎!!ឆ្ងាយដែរ?

ខ៖ ឆ្ងាយណាស់ដាច់ស្រយាលហោស

ក៖ ប៉ុន្តែអ៊ុំនឹងធ្វើការនឹងនៅខេត្តខ្លួនឯងទេ?

ខ៖ ចា៎!!នៅខេត្តខ្លួនឯងនឹង

ក៖ គេមិនជំលាសអោយទៅខេត្តផ្សេងទេហោសអ៊ុំ?

ខ៖ អត់ទេអត់មានទេនឹងនៅខេត្តខ្លួនឯងនឹងតែម្តងនឹង

ក៖ អូ៎!!បាទអ៊ុំបាទ ចុះពេលដែរដាច់ពលពតនឹងជំនាន់ណុងចូលជំនាន់អីផ្សេងទៀតដែរអ៊ុំ?

ខ៖ គ្មានជំនាន់អីតៀតទេក្មួយ

ក៖ ដាច់ពលពតអស់ហើយណាអ៊ុំ?

ខ៖ ចា៎!!បើឆ្នាំ1970នឹងវាមានខ្មែរក្រហមនឹងហាស មានខ្មែរស

ក៖ វាមានពួកយាគកុងដែរណាអ៊ុំ?

ខ៖ ចា៎!!មានពួកយាគកុងយាគអីណុង ដល់រួចអីពីនឹងទៅបានចូលអាពតនឹង

ក៖ ចូលអាពតនឹងហោសអ៊ុំ?

ខ៖ មុនដំបូងនឹងខ្មែរស ខ្មែរសហើយខ្មែរក្រហមនឹង

ក៖ ពួកយាគកុងនឹងហោសអ៊ុំ?

ខ៖ ពួកយាគកុងនឹង

ក៖ ហើយបានចូលជំនាន់ពលពតទៅដល់ពេលដែរដាច់ពលពតនឹងមកយើងចូល?

ខ៖ ពេលដែរដាច់ពលពតនឹងមកជំនាន់

កៈ ខ្មែរយើងធម្មតា?

ខៈ ហើយបានចូលខ្មែរយើងនឹងគណៈបក្សយើងនឹង

កៈ ចុះកាលពីដាច់ពលពតថ្មីៗនឹងយើងនៅមានការលំបាកដដែរតើហីអ៊ុំ?

ខៈ លំបាកណាស់ក្មួយអើយវាលំបាកណាស់

កៈ ដោយសារតែកាលណុងយើងត្រូវរកលុយដើម្បីចិញ្ចឹមជីវិតណាអ៊ុំ?
ខៈ ចាំ!!រកលុយចិញ្ចឹមជីវិតនឹង
ដើរដងត្រីងដងអីចឹងទៅហើយអាពតនឹងវាធ្វើអាងដាក់ត្រីហើយនាំគ្នានឹង
បានបារយកមកដូរជាអង្ករហូបនឹងទៅ

កៈ អូ៎!!ចឹង?

ខៈ លំបាកណាស់ហើយទៅអ៊ុំមានតែស្រីៗនឹងហើយនឹងមានតែលោកពុកមួយនឹងឯង
ទៅណាក៏លោកពុកនឹងទៅនាំដឹងមុខនឹងលោកពុកនឹងនាំរកទៅរកនេះរកនោះ

កៈ
បាទអ៊ុំចុះអ៊ុំគិតថានៅពេលដែរអ៊ុំបានគ្រួសារជាមួយអ៊ុំប្រុសនឹងអ៊ុំមានការលំបាកអីជាមួយ
គ្នាដែរអ៊ុំ?

ខៈ អត់លំបាកទេ

កៈ អត់សូវលំបាកទេហោសអ៊ុំ?

ខៈ អត់សូវលំបាកទេ

កៈ ចុះអ៊ុំគិតថាការលំបាកនឹងកាលពីជំនាន់ពលពតនឹង
មុនពលពតនឹងអ៊ុំគិតថាអ៊ុំឆ្លងកាត់វាដោយរបៀប ណាដែរអ៊ុំ?

ខៈ ចាំ!!ថាម៉េច?

កៈ ជំនះឧបសគ្គការលំបាករបស់អ៊ុំនឹងដោយរបៀបណាដែរ?

ខៈ អូយនិយាយពីអាពតនឹងហោស

កៈ និយាយពីអ៊ុំជំនះឧបសគ្គហាស?

ខ៖ ជំនះឧបសគ្គនឹងដូចជាគ្មានទេក្មួយអើយមានតែជំនាន់អាពតនឹងឯង

ក៖ បាទអ៊ុំឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរ?

ខ៖ ការលំបាកហើយលំបាកដែរដូចអ៊ុំប្រាប់អោយក្មួយឯងចឹងថាអ៊ុំវែកដី វែកធ្លីនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ កាប់ឈើកាប់ព្រៃនឹង គេអោយបោចវល្លិ៍បោចអីច្រើនដែរណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ និយាយរៀបរាប់វាមិនអស់ទេនឹង

ក៖ រាប់មួយថ្ងៃនឹងក៏មិនទាន់អស់ដែរណាអ៊ុំ?

ខ៖ ចា៎!!មិនអស់ទេនឹងបើនិយាយពីជំនាន់អាពតនឹងមកនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ គេអោយឡើងភ្នំចុះភ្នំនឹងទៅហើយរុកព្រៃរុកអីទៅហើយនឹង

ក៖ ចេះតែទៅហើយនឹងប៉ុន្តែមិនដឹងថាទៅណាទេ?

ខ៖ ចេះតែទៅហើយនឹងមិនដឹងថាទៅណាទេនឹង
ហើយគ្មានពេលបានឃើញថ្ងៃចឹងទេវាអោយដើរចូល
ទៅក្នុងព្រៃហើយនឹងងងឹតឈឹងនឹងចេះតែតាមវាចឹងទៅ

ក៖ អូ៎!ថ្ងៃចឹងយើងអត់ដឹងថាពេលថ្ងៃទេណាអ៊ុំ?

ខ៖ អត់ដឹងទេចុះបើព្រៃស្អុកនឹងនាំចូលព្រៃនឹងទៅរកថ្ងៃនៅណាឃើញទៅ

ក៖ ចឹងអត់ដឹងថានៅណាទេ?

ខ៖ អត់ដឹងថានៅណាទេនឹងដល់កន្លែងទីស្នាក់ការគេនឹងឧបម៉ាថា
ដល់ទីស្នាក់ការចឹងបានគេអោយឈប់នឹងទៅ ចឹងទេចេះតែដើរមួយយប់ទល់ភ្លឺចឹងទៅ

ក៖ ចេះតែដើរតាមគេនឹងទៅគេមានមេដឹកនាំគេទៅ?

ខ៖ ដើរតាមគេគេមានមេដឹកនាំយើងទៅនឹង យើងចេះតែទៅតាមគេទៅណាស់ក្មួយ

កៈ បាទអ៊ុំបាទ
ចឹងដូចជាអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ?

ខៈ ទេអារឿងសប្បាយនឹងទុកអោយស្មើរគ្នានឹងណាស់ក្មួយវាចេះតែទៅហើយនឹង
យើងមិនសូវមានទុក ព្រួយប៉ុន្មាននឹងទេ ចំណាស់នេះទៅហើយនឹងចឹងខ្ចិលហាស

កៈ បាទអ៊ុំចូលអ៊ុំគិតថានៅពេលដែរអ៊ុំការនឹងអ៊ុំសប្បាយទេអ៊ុំ?
ខៈ ទេកាលពីដែរជួបជុំគ្នានឹងសប្បាយដែរនឹង

កៈ អូ៎!!បាទអ៊ុំគិតថាពេលដែរអ៊ុំការអី
រឺមួយក៏ពេលដែរអ៊ុំជួបជុំកូនអីនឹងអ៊ុំគិតថាសប្បាយទេ?

ខៈ សប្បាយក្មួយដូចថារៀបអោយកូនមានសុភមង្គលនឹងសប្បាយដែរ

កៈ បាទអ៊ុំចុះអ៊ុំមានកូនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានកូន3នាក់នឹង

កៈ ប៉ុន្តែពួកគាត់រៀបការហើយអស់ហើយមែនទេអ៊ុំ?
ខៈ គេរៀបការអស់ហើយនឹងនៅតែកូនពៅមួយនឹង

កៈ ប៉ុន្តែស្រីទាំងអស់រឺយ៉ាងម៉េចដែរអ៊ុំ?
ខៈ ប្រុសទាំង3នាក់នឹង

កៈ ប្រុសទាំង3នាក់នឹងហោសអ៊ុំ?
ខៈ ចា៎!!មួយនៅកំពង់ចាម

កៈ គាត់ទៅយកក្រុមគ្រួសារនៅកំពង់ចាមហោសអ៊ុំ?
ខៈ ចា៎!!យកអ្នកផ្សារបឹងកុក

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ចា៎!!ហើយមួយទៀតនឹងនៅស្អាងនឹង
ហើយអាពៅនឹងនៅជាមួយខ្ញុំនឹងរៀនជិតចប់សកវិទ្យាល័យនៅ
ឆ្នាំនេះឯងនៅតែ3ខែទៀតនឹងចប់ហើយនឹង

កៈ អូ!បាទអ៊ុំបាទ
អ៊ុំដូចជាកាលពីក្មេងនឹងអ៊ុំធ្លាប់មានក្ដីស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុំចង់ធ្វើអីទេ?

ខៈ
អ៊ុំហោសកាលពីដើមនឹងអ៊ុំស្រម៉ៃថាដល់ពេលដែរធំនឹងទៅអ៊ុំចង់ក្លាយជាជាងកាត់ដេរនឹង

កៈ អូ!!អ៊ុំចង់ធ្វើកាត់ដេរហោសអ៊ុំ?
ខៈ ដល់ពេលដែរអត់បានដូចបំណាងចឹងក៏មកលក់បង្អែមចឹងទៅណាស់

កៈ អូ!!បាទអ៊ុំ
ចុះបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗនឹងតើអ៊ុំចង់ផ្ដែផ្ដាំអីទៅគាត់ដែរទៅអ៊ុំ?

ខៈ មិនដឹងផ្ដែផ្ដាំថាម៉េចផងនឹង

កៈ
ចង់និយាយថាចង់អោយគាត់ខំប្រឹងរៀនដើម្បីមានអនាគត់ល្អអីចឹងហាសទាំងកូននឹងទាំងចៅចឹង ហាសអ៊ុំ?

ខៈ មានតែប៉ុណ្ណឹងឯងក្មួយ
ដូចថាអោយកូននឹងដាស់តឿនកូនចៅជំនាន់ក្រោយអោយខំប្រឹងឡើងដើម្បីអនាគត់ខ្លួនឯងចឹងហាស
ដើម្បីធ្លាប់ជីវិតដូចថាខ្ញុំអីចឹងកំសត់កំរជំនាន់នោះមកហើយតែជំនាន់ក្មេងៗសារក្រោយនឹងហាសអោយចេះខំប្រឹងរៀនសូត្រ

កៈ អោយចេះតស៊ូហាសណអ៊ុំ?
ខៈ
អោយចេះតស៊ូនឹងគេមួយជីវិតមួយជំនាន់ខ្ញុំនឹងមួយជំនាន់ម៉ែរបស់ខ្ញុំនឹងអោយចេះតស៊ូនឹង

កៈ
បាទអ៊ុំចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើអ៊ុំចង់អោយពួកគាត់ជៀសវៀងអីគេដែរអ៊ុំ?

ខៈ ជៀសវៀងអាគ្រឿងញៀន

កៈ អូ!គ្រឿងញៀនហោសអ៊ុំ?

ខៈ នឹងអាចោរឆក់ប្លន់គេប៉ុណ្ណឹងហើយទោះយើងអត់យ៉ាងណាក៏ដោយខំប្រឹងរកទៅនឹង

កៈ បានប៉ុណ្ណាយកប៉ុណ្ណឹងហាសណាអ៊ុំ?

ខៈ ចា៎!!កុំសំលាប់កាប់ចាក់គ្នាអីកុំអោយស្លាប់ដោយសារតែអាចង់បានរបស់គេនោះនឹង សុំតែផ្ដាំតែប៉ុណ្ណឹងទេធ្វើម៉េចជៀសវៀងនឹង បើថាប្លន់គេហើយអោយគេមានជីវិតទៅ ខ្លួនក៏ចង់រស់ហើយ គេនឹងក៏ចង់រស់ដែរចង់យកអីក៏យកទៅ ចាមានតែប៉ុណ្ណឹងឯងក្មួយ

កៈ បាទកុំព្យាយាមធ្វើបាបគេនឹងហោសអ៊ុំ?

ខៈ
ចា៎!!កុំធ្វើបាបណាស់ក្មួយអ៊ុំហាសសូម្បីតែកណ្ដុរក៏អ៊ុំចិញ្ចឹមកណ្ដុរដែរណាស់ដល់ពេលដែរ កណ្ដុរនឹង បានស្លាប់បាត់ទៅនឹងអ៊ុំអាណិតហាសណាស់
ដល់ពេលដែរចឹងហើយបានធ្វើអោយរបស់របរអ៊ុំនឹង
ទាំងប៉ុន្មានបើដែរអោយកណ្ដុរណាខាំបន្តិចទេ

កៈ បាទអ៊ុំចឹងមានអីដែរអ៊ុំចង់ប្រាប់ទៀតអត់អ៊ុំ?

ខៈ អត់ទេក្មួយអត់មានអីទេនឹង

កៈ
បាទអ៊ុំចឹងជាចុងក្រោយនឹងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំដែរបានទា ក់ទងពី ប្រវត្តិរបស់អ៊ុំចឹងហាសអ៊ុំ?

ខៈ ចា៎!!នឹងហើយ

កៈ ហើយចឹងខ្ញុំបានអរគុណច្រើនដែរចឹងហាសអ៊ុំ៕៕៕